**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន
និង សង្គ្រោះជនពិការដោយសារមីន

លេខ : ៧៤៧ /..អន../..អចម../..២០២៦

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹងវិធានការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (មីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម) ក្នុងពេល និងក្រោយពេលគ្រោះទឹកជំនន់

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) សូមជម្រាបជូនដល់សាធារណជនមេត្តាជ្រាបថា យោងតាមសេចក្តីជូនដំណឹងស្តីពីស្ថានភាពអាកាសធាតុរបស់ក្រសួងធនធានទឹក និងឧតុនិយម ព្រះរាជាណាចក្រកម្ពុជាកំពុងទទួលរងនូវឥទ្ធិពលព្យុះទី៩ ឈ្មោះបាវី (Bavi)T2609 និងព្យុះទី១១ ឈ្មោះហៃសិន (Haishen)T2611 ដែលអាចធ្វើឱ្យរាជធានី ខេត្តមួយចំនួនរងឥទ្ធិពលទឹកភ្លៀងដែលអាចបង្កជាទឹកជំនន់។

ក្នុងពេល និងក្រោយពេលទឹកជំនន់ យុទ្ធភណ្ឌគ្រឿងផ្ទុះមួយចំនួនត្រូវបានប្រទះឃើញ ដោយសារការហូរច្រោះដីរសាត់មកពីតំបន់ដែលមានមីនប្រឆាំងមនុស្ស មីនប្រឆាំងយានយន្ត គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមជាច្រើនប្រភេទ ដែលអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋជាយថាហេតុ ជាពិសេសប្រជាពលរដ្ឋកំពុងរស់នៅតំបន់ដែលរងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះទាំងនោះ។

ដើម្បីបង្ការនិងទប់ស្កាត់បាននូវគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងពេល និងក្រោយពេលគ្រោះទឹកជំនន់ អាជ្ញាធរមីនសូមធ្វើការណែនាំដល់គ្រប់គណៈកម្មាធិការសកម្មភាពមីនរាជធានី ខេត្ត គ្រប់ប្រតិបត្តិករអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ ចូលរួមសហការអនុវត្តនូវវិធានការបន្ទាន់មួយចំនួនដូចខាងក្រោម៖

១- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលអាចមកជាមួយទឹកជំនន់ ដោយសារការហូរច្រោះដីរសាត់មកពីតំបន់ដែលមានមីនប្រឆាំងមនុស្ស មីនប្រឆាំងយានយន្ត គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមជាច្រើនប្រភេទ។

២- ណែនាំឱ្យប្រជាពលរដ្ឋរាយការណ៍មកអាជ្ញាធរមូលដ្ឋាន មេភូមិ មេឃុំ ឬ ប្រតិបត្តិករបោសសម្អាតមីនដែលនៅក្បែរនោះជាបន្ទាន់ នៅពេលប្រទះឃើញយុទ្ធភណ្ឌគ្រឿងផ្ទុះ។

៣- រៀបចំខ្លឹមសារផ្សព្វផ្សាយ និងផលិតជាសម្ភារអប់រំ ស្តីពីគ្រោះថ្នាក់ដែលអាចបង្កឡើងដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុង និងក្រោយពេលទឹកជំនន់ សម្រាប់ផ្តល់ជូនភ្នាក់ងារអប់រំ

៤- ឆ្លើយតបឱ្យបានទាន់ពេលវេលា ក្នុងការប្រមូលយកទៅកម្ទេចចោលនូវយុទ្ធភណ្ឌគ្រឿងផ្ទុះដែលប្រជាពលរដ្ឋបានរាយការណ៍។

៥- ដាក់ស្លាកសញ្ញាសម្គាល់ជាបន្ទាន់នៅតាមតំបន់សង្ស័យមានយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលអាចហូរតាមទឹក និងដីល្បាប់ ដើម្បីទប់ស្កាត់កុំឱ្យប្រជាពលរដ្ឋចូលទៅស្នាក់នៅ ឬ ឆ្លងកាត់។

៦- សូមបងប្អូនប្រជាពលរដ្ឋនៅពេលប្រទះឃើញវត្ថុសង្ស័យជាគ្រាប់មីនប្រឆាំងមនុស្ស មីនប្រឆាំងយានយន្ត គ្រាប់បែកចង្កោម និង គ្រាប់មិនទាន់ផ្ទុះ សូមកុំរើស កាន់ គប់ ដំ កែច្នៃគ្រាប់ទាំងនោះ វាបណ្តាលឱ្យរបួស ពិការ ស្លាប់ គ្រប់ពេល។

៧- សូមបងប្អូនប្រជាពលរដ្ឋនៅពេលប្រទះឃើញគ្រាប់មីនប្រឆាំងមនុស្ស មីនប្រឆាំងយានយន្ត គ្រាប់បែកចង្កោម និង គ្រាប់មិនទាន់ផ្ទុះសូមរាយការណ៍ជាបន្ទាន់មកកម្លាំងប្រដាប់អាវុធ នគរបាលជាតិ អាជ្ញាធរមូលដ្ឋាន មេឃុំ មេភូមិ ឬ ប្រតិបត្តិករបោសសម្អាតមីន ដែលនៅក្បែរនោះ ដើម្បីយកគ្រាប់ទាំងនោះទៅកម្ទេចចោល។

ទទួលបានសេចក្តីណែនាំនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាប្រធានគណៈកម្មាធិការសកម្មភាពមីនខេត្ត គ្រប់ប្រតិបត្តិករជាតិ និងអន្តរជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមសហការ និងអនុវត្តតាមការគួរ។

ថ្ងៃ ព្រហស្បតិ៍ ៧ កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២៦

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី១**

CMAA

**បណ្ឌិត លី ធុជ**

<u>ចម្លងជូន៖</u>

- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ «ដើម្បីសហការ»
- គណៈកម្មាធិការសកម្មភាពមីនរាជធានី ខេត្ត «ដើម្បីអនុវត្ត»
- គ្រប់ប្រតិបត្តិករអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ